# លោក ហ៊ុន សែន បញ្ជាឱ្យសមត្ថកិច្ចតាមចាប់ខ្លួនអ្នកលេងហ្វេកប៊ុកម្នាក់រឿងបញ្ចេញមតិរិះគន់លោក។



លោក ហ៊ុន សែន ថ្លែងនៅក្នុងពិធីបើកការដ្ឋានសាងសង់ពង្រីក និងលើកគុណភាព កំណាត់ផ្លូវជាតិលេខ៧ ពីស្គន់ទៅក្រុងកំពង់ចាម នៅព្រឹកថ្ងៃទី៩ ខែមករា ឆ្នាំ២០២៣។

លោក ហ៊ុន សែន បញ្ជាឱ្យសមត្ថកិច្ចតាមចាប់ខ្លួនអ្នកលេងហ្វេកប៊ុកម្នាក់ដោយសាររឿងបញ្ចេញមតិរិះគន់លោកក្នុងពេលលោកកំពុងបំពេញទស្សនកិច្ចនៅប្រទេសម៉ាល់ឌីវ (Maldives)។មន្ត្រីសង្គមស៊ីវិលលើកឡើងថា សង្គមប្រជាធិបតេ

យអ្នកដឹកនាំគួរបើកចិត្តទទួលយកមតិរិះគន់ពីមជ្ឈដ្ឋាននានា ដើម្បីយកទៅកែលម្អក្នុងការដឹកនាំប្រទេស។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលគេស្គាល់ទូទៅថា ជាមេដឹកនាំចូលចិត្តមតិលើកបញ្ចើចបញ្ចើ តែមិនចេះទទួលយកមតិទិតៀនពីសាធារណៈជននោះ នៅថ្ងៃទី១៥ ខែមករា  បានបញ្ជាឱ្យប៉ូលិសតាមចាប់ខ្លួនម្ចាស់គណនីហ្វេកប៊ុក (Facebook) ម្នាក់ ដាក់ឈ្មោះថា «Ver To» ដែលបានចូលទៅបញ្ចេញមតិ (Comment) រិះគន់ចំពោះការដឹកនាំរបស់លោក។

ប្រតិកម្មរបស់លោក ហ៊ុន សែន នេះគឺបន្ទាប់ពីលោកបានបង្ហោះរូបថតជាង ១០ ស្លឹកនៅឆ្នេរសមុទ្រមួយកន្លែងនៃប្រទេសម៉ាល់ឌីវ (Maldives) ដោយលោកសរសេរថា «ឆ្លៀតមុជទឹកសមុទ្រប្រទេសម៉ាល់ឌីវ ដែលកន្លែងមុជទឹកនៅជាប់ជាមួយបន្ទប់ស្នាក់នៅទាំងទឹកប្រៃនិងទឹកសាប»។ បន្ទាប់មកអ្នកលេងហ្វេកប៊ុកម្នាក់ឈ្មោះ «Ver To» បានចូលទៅខុមមេនឌីដងដោយសរសេរថា «មែនហើយពុក ឆ្នេរសមុទ្រយើងស្អាតជាងគេ តែអ្នកដឹកនាំស្រុកយើងស្មោកគ្រោកជាងគេលើលោក មែនអត់ពុក»។ ភ្លាមៗនោះលោក ហ៊ុន សែន សរសេរឆ្លើយតបដោយគំរាមថា«នេះជាសំដីមនុស្សពាល សូមនគរបាលស្វែងរកបន្ទាន់ តើវានៅឯណា»។

ស្របពេលការបោះឆ្នោតជាតិអាណត្តិទី៧ខិតជិតមកដល់ លោក ហ៊ុន សែន ហាក់មមាញឹកប្រើប្រាស់ហ្វេសប៊ុករបស់លោក ក៏ប៉ុន្តែលោកមិនមែនចំណាយពេលវេលាជានាយករដ្ឋមន្ត្រីប្រើប្រាស់ហ្វេសប៊ុកដើម្បីជាប្រយោជន៍ដោះស្រាយបញ្ហាជាតិសំខាន់ៗ ឬសំណូមពរទូទៅរបស់ពលរដ្ឋនោះទេ។ លោក ហ៊ុន សែន ប្រើប្រាស់ហ្វេសប៊ុក ដើម្បីតាមដាន គំរាមកំហែងតាមចាប់អ្នកទាំងឡាយណាដែលហ៊ានចូលមករិះគន់លោក។ លោក ហ៊ុន សែន មិនត្រឹមតែខ្លាចការរិះគន់ អំពីរឿងអសមត្ថភាពក្នុងការដឹកនាំប្រទេសជាតិនោះទេ ជាក់ស្តែងថ្មីៗនេះសូម្បីតែរឿងយុវជន ស្ទូង

នាគព័ន្ធ រិះគន់លោកអំពីការភ្ញាល់បាលទាត់ពិភពលោកចាញ់គេ ក៏លោកខឹងសម្បា និងប្រកាសតាមរកឪពុកម្ដាយយុវជននោះដល់ផ្ទះដែរ ខណៈអ្នករិះគន់លោកមួយចំនួននៅបន្តជាប់ពន្ធនាគាររហូតដល់សព្វថ្ងៃនេះ។

ប្រធានសមាគមការពារសិទ្ធិមនុស្សអាដហុក (Adhoc) លោក នី សុខា លើកឡើងថា លោកមិនគាំទ្រការបញ្ចេញមតិបែបអសុរោះនោះទេ។ ទោះយ៉ាងណា លោកថា ការបញ្ចេញមតិក្នុងសង្គមប្រជាធិបតេយ្យជារឿងល្អដើម្បីចូលរួមស្ថាបនា សង្គមស្របតាមគោលការណ៍សិទ្ធិមនុស្សអន្តរជាតិដែលបើកទូលាយឱ្យពលរដ្ឋបញ្ចេញមតិដោយគ្មានការភ័យខ្លាច។ លោកយល់ថា ការប្រើប្រាស់វិធានការផ្លូវច្បាប់លើអ្នកបញ្ចេញមតិ គឺជាសញ្ញាមួយគួរឱ្យព្រួយបារម្ភដែលធ្វើឱ្យអ្នកទាំងឡាយណាដែលមានទស្សនៈនយោបាយផ្ទុយពីរដ្ឋាភិបាលភ័យខ្លាចក្នុងការបញ្ចេញមតិយោបល់៖

លោក នី សុខា៖ *«រដ្ឋាភិបាលត្រូវតែមានការបើកសិទ្ធិឱ្យបានទូលំទូលាយដោយធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋរបស់ខ្លួនមានឱកាសប្រើប្រាស់នូវសិទ្ធិសេរីភាពបញ្ចេញមតិដោយគ្មានការភ័យខ្លាច ហើយបើសិនរដ្ឋាភិបាលចង់រឹតត្បិតសេរីភាពក្នុងការបញ្ចេញមតិហ្នឹងទាល់តែរដ្ឋាភិបាលមានមូលដ្ឋានពន្យល់ឱ្យបានច្បាស់លាស់ថាអ្នកបញ្ចេញមតិហ្នឹងធ្វើឱ្យមានភាពវឹកវរដល់សង្គម អាហ្នឹងទើបអាចរឹតត្បិតបាន»*។

ស្រដៀងគ្នានេះដែរ អគ្គលេខាធិការសហព័ន្ធនិស្សិតបញ្ញវន្តកម្ពុជាលោក គៀន ពន្លក មើលឃើញថា កន្លងមកអ្នកដែលហ៊ានរិះគន់ការដឹកនាំលោក ហ៊ុន សែន ឬរដ្ឋាភិបាលរបស់លោក តែងតែប្រឈមនឹងការចោទប្រកាន់ ចាប់ខ្លួន និងប្ដឹងរឹបអូសយកទ្រព្យសម្បត្តិជាបន្តបន្ទាប់។ លោកបន្តថា ការស្វែងរកចាប់ខ្លួនអ្នកបញ្ចេញមតិនៅលើបណ្ដាញសង្គមបែបនេះបាននាំឱ្យសេរីភាពបញ្ចេញមតិនៅកម្ពុជាកាន់តែរួមតូចគួរឱ្យព្រួយបារម្ភ។ យ៉ាងណាក្ដី លោក គៀន ពន្លក យល់ថា ក្នុងសង្គមប្រជាធិប

តេយ្យពលរដ្ឋមានសិទ្ធិទិតៀនមេដឹកនាំ ឬបុគ្គលសារធារណៈ ដើម្បីកែប្រែចំណុចខ្វះខាតឱ្យប្រសើរឡើង។

លោក គៀន ពន្លកៈ *«សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន គឺជាបុគ្គលសាធារណៈមួយ អ៊ីចឹងប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិសេរីភាពយ៉ាងពេញលេញក្នុងការបញ្ចេញមតិយោបល់ ឬក៏រិះគន់បែបស្ថាបនាទៅលើរូបគាត់ បើសិនគាត់ធ្វើអ្វីខុសមួយ។ បើសិនមេដឹកនាំមួយប្រជាពលរដ្ឋ ឬអ្នកនយោបាយរិះគន់មិនបាន អ៊ីចឹងមិនមែនជាមេដឹកនាំកើតឡើងក្នុងសង្គមប្រជាធិបតេយ្យនោះទេ»*។

ប្រធានអង្គភាពអ្នកនាំពាក្យរដ្ឋាភិបាល លោក ផៃ ស៊ីផាន បដិសេធមិនឆ្លើយតបរឿងនេះ ដោយលោករុញឱ្យទៅសួរខាងអាជ្ញាធរមានសមត្ថកិច្ចវិញ។ វិទ្យុអាស៊ីសេរីមិនអាចទាក់ទងអ្នកនាំពាក្យក្រសួងមហាផ្ទៃលោក ខៀវ សុភ័គ និងអ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិលោក ឆាយ គឹមខឿន ដើម្បីបញ្ជាក់ជុំវិញរឿងនេះបានទេនៅថ្ងៃទី១៦ ខែមករា។

សិទ្ធិសេរីភាពបញ្ចេញមតិ ត្រូវបានធានាដោយច្បាប់ជាតិ និងសន្ធិសញ្ញាអន្តជាតិ។ ជនគ្រប់រូបមានសិទ្ធិសំដែងកង្វល់ និងទស្សនៈរបស់ខ្លួនដោយសេរីដោយគ្មានការជ្រៀតជ្រែកពីរដ្ឋាភិបាល។ ទោះយ៉ាងណា មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាហៅកាត់ថា (CCHR) បានរកឃើញថា ក្នុងរយៈពេល១០ខែឆ្នាំ២០២២ អាជ្ញាធរនៅតែបន្តរឹតត្បិតនិងរំលោភបំពានសិទ្ធិសេរីភាពនៃការបញ្ចេញមតិចំនួន ១១០ដងទៅលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ក្នុងនោះរួមមានសកម្មជនបរិស្ថាន សហជីព និងបុគ្គលិកអង្គការសង្គមស៊ីវិលជាដើម។ ពួកគេត្រូវបានកោះហៅទៅសាកសួរ ឃុំខ្លួនឬចាប់ខ្លួនដោយចោទប្រកាន់ពីបទបរិហារកេរ្តិ៍ និងបទញុះញង់ ហើយអ្នកខ្លះទៀតត្រូវបានអាជ្ញាធរបង្ខំឲ្យផ្ដិតមេដៃលើកិច្ចសន្យាជាថ្នូរនឹងការដោះលែងទាក់ទងការបញ្ចេញមតិរបស់ពួកគេ៕